**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៤៦១ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៤

នាយកដ្ឋាន ... លិខិតឆ្លងដែន
លេខ 195
ថ្ងៃទី 02 ខែ 05 ឆ្នាំ 2014
ហត្ថលេខា...

# ប្រកាស
## ស្តីពី
## បែបបទ នៃការផ្តល់លិខិតឆ្លងដែនធម្មតា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០៨ ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការ
- បានឃើញអនុក្រឹត្យលេខ៩៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យលេខ ៦៨ អនក្រ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៩៦៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនី សិស្ស និស្សិតខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ :** ការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលរដ្ឋខ្មែរទាំងពីរភេទត្រូវកំណត់លក្ខខណ្ឌ ដូចខាងក្រោម :

ក. ពលរដ្ឋដែលមានអាយុពី១៥ឆ្នាំឡើង ត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ [illegible]

ដែលបញ្ជាក់ថាសញ្ជាតិខ្មែរ និងឯកសារសម្គាល់គ្រួសារ ឬ ឯកសារផ្សេងទៀតដែលបញ្ជាក់អំពី អត្តសញ្ញាណ សញ្ជាតិ និងទីលំនៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ។

ខ. កុមារដែលមានអាយុក្រោម១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី ឪពុក ម្តាយ ឬអាណាព្យាបាល និងត្រូវភ្ជាប់មកជាមួយនូវឯកសារនានាដូចមានចែងក្នុងចំណុចក ប្រការ១ នៃប្រកាសនេះ ។

**ប្រការ២ :** លិខិតឆ្លងដែនធម្មតា គឺជាឯកសារបញ្ជាក់ថា ជនដែលកាន់លិខិតឆ្លងដែននោះ ជាពលរដ្ឋខ្មែរដែលមានសិទ្ធិសុំទិដ្ឋាការឆ្លងដែនបាន ។ មនុស្សម្នាក់មិនត្រូវបានអនុញ្ញាតឱ្យផ្តល់ ឬប្រើប្រាស់លិខិតឆ្លងដែនធម្មតាលើសពីមួយឡើយ ។

**ប្រការ៣ :** លិខិតឆ្លងដែនធម្មតាមានសុពលភាពរយៈពេល៥ឆ្នាំសម្រាប់កុមារមានអាយុពី០ឆ្នាំដល់៥ឆ្នាំ និងមានសុពលភាពរយៈពេល១០ឆ្នាំសម្រាប់អ្នកមានអាយុពី៦ឆ្នាំឡើង ។

**ប្រការ៤ :** ស្ថាប័នមានភារកិច្ចផ្តល់លិខិតឆ្លងដែនធម្មតា មានសិទ្ធិបដិសេធមិនផ្តល់លិខិតឆ្លងដែន ឃាត់លិខិតឆ្លងដែនទុក ឬបដិសេធលិខិតឆ្លងដែនដែលបានផ្តល់រួចហើយ ក្នុងករណីដូចតទៅ ÷

- ជនដែលមានសំណើពីស្ថាប័នមានសមត្ថកិច្ចសុំមិនឱ្យផ្តល់លិខិតឆ្លងដែន
- ជនដែលមានការសម្រេចពីតុលាការហាមឃាត់ការចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- ពិរុទ្ធជន ទណ្ឌិត ឬជនកំពុងមានដីកាបង្គាប់ឱ្យចាប់ខ្លួន
- លិខិតឆ្លងដែនដែលក្លែង ឬលិខិតឆ្លងដែនដែលបាត់ ។

**ប្រការ៥ :** អ្នកសុំលិខិតឆ្លងដែនធម្មតា ចាំបាច់ត្រូវ ÷

- បំពេញពាក្យសុំលិខិតឆ្លងដែនមួយច្បាប់ ។ មានបិទរូបថត ចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីជនតាមគំរូឯកភាព
- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ
- ថតរូប ផ្តិតស្នាមម្រាមដៃ និងចុះហត្ថលេខាផ្ទាល់នៅនាយកដ្ឋានលិខិតឆ្លងដែន ឬសាខាលិខិតឆ្លងដែនប្រចាំតំបន់
- បង់អាករលិខិតឆ្លងដែនតាមការកំណត់នៃប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ៦ :** ស្ថាប័នមានភារកិច្ចផ្តល់លិខិតឆ្លងដែនធម្មតា ត្រូវ ÷

- ទទួលសំណុំឯកសារសុំលិខិតឆ្លងដែនរបស់ពលរដ្ឋ ពិនិត្យឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់
- ថតរូប ផ្តិតស្នាមម្រាមដៃ យកហត្ថលេខាបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ និងផ្តិតរូបថត ៤×៦ ចំនួនមួយសន្លឹកបិទលើពាក្យសុំលិខិតឆ្លងដែន
- ធ្វើសម្ភាសន៍បញ្ជាក់អំពីចំណុចចាំបាច់មួយចំនួន យកភិនភាគ ស្លាកស្នាម និងវាស់កម្ពស់
- ទទួលប្រាក់អាករ សរសេរនឹងប្រគល់បង្កាន់ដៃ
- បំពេញទិន្នន័យ ត្រួតពិនិត្យ បោះពុម្ព និងប្រគល់លិខិតឆ្លងដែនជូនអ្នកសុំ

**ប្រការ៧ :** លិខិតឆ្លងដែនធម្មតាដែលត្រូវបានអនុញ្ញាតឱ្យផ្តល់ដោយអាករជាបន្ទុករបស់រដ្ឋ ត្រូវមានសំណើសុំពីប្រធានក្រសួង ស្ថាប័នសាមី ឬការបញ្ជាក់ពីប្រធានក្រសួង ស្ថាប័នអាណាព្យាបាល និងត្រូវមានការពិនិត្យសម្រេចដោយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ។

**ប្រការ៨ :** លិខិតឆ្លងដែនធម្មតាត្រូវផ្តល់ជូនពលរដ្ឋក្នុងរយៈពេលយ៉ាងយូរ២០ ថ្ងៃ នៃថ្ងៃធ្វើការ ។ រយៈពេលនេះគិតពីថ្ងៃដែលសាមីជនបានបំពេញបែបបទត្រឹមត្រូវគ្រប់គ្រាន់នៅនាយកដ្ឋានលិខិតឆ្លងដែន ឬសាខាលិខិតឆ្លងដែនប្រចាំតំបន់ ។

**ប្រការ៩ :** ប្រគល់សមត្ថកិច្ចជូនអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មពិនិត្យ និងសម្រេចលើការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលរដ្ឋតាមបែបបទ និងលក្ខខណ្ឌ ដូចមានចែងក្នុងប្រកាសនេះ ។

**ប្រការ១០ :** ជនណាដែលប្រព្រឹត្តអំពើ ÷

- ផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទសុំផ្តល់លិខិតឆ្លងដែនធម្មតា
- កាន់កាប់ ឬប្រើប្រាស់លិខិតឆ្លងដែនធម្មតា ដែលខ្លួនគ្មានសញ្ជាតិខ្មែរ
- ក្លែង កោស លុប ឬសរសេរត្រួតលើលិខិតឆ្លងដែនធម្មតា
- មានចេតនាជួយសម្រួលសំណុំបែបបទ ឬសម្រេចផ្តល់លិខិតឆ្លងដែនធម្មតា ដល់ជនដែលគ្មានសញ្ជាតិខ្មែរ ។

ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**ប្រការ១១ :** ប្រកាសលេខ ៤០៧ ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៤ និងប្រកាសលេខ ២១២ ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីបែបបទនៃការផ្តល់លិខិតឆ្លងដែនធម្មតា ប្រកាសលេខ ៦១១ ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ ស្តីពីបែបបទនៃការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនី កម្មសិក្សាការីខ្មែរទៅធ្វើការ ឬកម្មសិក្សាដោយស្របច្បាប់នៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១២ :** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានលិខិតឆ្លងដែន និងប្រធានអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១២
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ